ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី ១២ លេខ ៩៦ សប្តាហ៍ទី ៤ ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១២

រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

តម្លៃជាវ

១ ច្បាប់	៥.០០០ រៀល
១ ខែ	៤០.០០០ រៀល
៣ ខែ	១២០.០០០ រៀល
៦ ខែ	២៤០.០០០ រៀល
១២ ខែ	៤៨០.០០០ រៀល

(ត្រូវបង់តម្លៃជាវជាមុន)

តារាង

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច សារាចរ ប្រកាស

p

p

ក

មាតិកា

I-ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

១៥.១២.២០១២ - ព្រះរាជក្រឹត្យ នស/រកត/១២១២/១០៤៤ ស្ដីពី ការដំឡើងឋានន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយ៍ទោ ជូនលោកឧត្តមសេនីយ៍ត្រី **សត ណារិទ្ធិ** នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៩៩៤៧

១៥.១២.២០១២ - ព្រះរាជក្រឹត្យ នស/រកត/១២១២/១០៤៥ ស្ដីពី ការដំឡើងឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ត្រី ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ០៧ រូប ៩៩៤៨

១៥.១២.២០១២ - ព្រះរាជក្រឹត្យ នស/រកត/១២១២/១០៤៦ ស្ដីពី ការដំឡើងឋានន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយ៍ត្រី ជូនលោកវរសេនីយ៍ឯក **គីម យន** នៃក្របខ័ណ្ឌមន្ត្រី នគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៩៩៤៩

១៥.១២.២០១២ - ព្រះរាជក្រឹត្យ នស/រកត/១២១២/១០៤៩ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ថ្នាក់ដឹកនាំនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា និង ដៃគូសហប្រតិបត្តិការ ចំនួន ១៧ រូប ៩៩៥០

១៥.១២.២០១២ - ព្រះរាជក្រឹត្យ នស/រកត/១២១២/១០៥០ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ថ្នាក់ដឹកនាំ និង មន្ត្រីនិយោជិត នៃកំពង់ផែស្វយ័តភ្នំពេញ ចំនួន ៣២ រូប ៩៩៥១

១៥.១២.២០១២ - ព្រះរាជក្រឹត្យ នស/រកត/១២១២/១០៥១ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ប្រធាន និង អនុប្រធានទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) ប្រចាំព្រះរាជាណាចក្រកម្ពុជា និង នាយកប្រតិបត្តិនៃក្រុមហ៊ុន Korea Expressway Corporation ចំនួន ០៣ រូប ៩៩៥៣

១៥.១២.២០១២ - ព្រះរាជក្រឹត្យ នស/រកត/១២១២/១០៥២ ស្ដីពីការតែងតាំងឯកឧត្តម **សេង ឃួរលាង** ជាសមាជិកអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ មានឋានៈស្មើ រដ្ឋលេខាធិការ ៩៩៥៤

១៥.១២.២០១២ - ព្រះរាជក្រឹត្យ នស/រកត/១២១២/១០៥៣ ស្ដីពី ការដំឡើងឋានន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយ៍ទោ ជូនលោកឧត្តមសេនីយ៍ត្រី **ម៉ុញ សុធីវណ្ណា** នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៩៩៥៥

១៥.១២.២០១២ -ព្រះរាជក្រឹត្យ នស/រកត/១២១២/១០៥៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ការពារជាតិ តាមលំដាប់ថ្នាក់ ចំពោះ នាយនគរបាលជាតិជាន់ខ្ពស់ ចំនួន ១១២ រូប នៃក្រសួងមហាផ្ទៃ ៩៩៥៦

១៥.១២.២០១២ -ព្រះរាជក្រឹត្យ នស/រកត/១២១២/១០៥៥ ស្តីពី ការប្រោសព្រះរាជទាន នូវ គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជាតាមលំដាប់ថ្នាក់ ចំពោះអស់លោក ចំនួន ៥០ រូប ៩៩៦០

១៥.១២.២០១២ -ព្រះរាជក្រឹត្យ នស/រកត/១២១២/១០៥៦ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតូបការ ចំពោះ ឧកញ៉ា **ខូច សម្បត្តិ** ៩៩៦២

១៩.១២.២០១២ -ព្រះរាជក្រឹត្យ នស/រកត/១២១២/១០៥៧ ស្តីពី ការដំឡើងឋានន្តរស័ក្តិពីវរមន្ត្រីទៅឧត្តមមន្ត្រី ជូនមន្ត្រីរាជការ ០៤ រូប នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៃក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ៩៩៦៣

១៩.១២.២០១២ -ព្រះរាជក្រឹត្យ នស/រកត/១២១២/១០៥៨ ស្តីពី ការតែងតាំងឯកឧត្តមចំនួន ០៣ រូប ជាទីប្រឹក្សាអមក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ មានឋានៈស្មើអនុរដ្ឋលេខាធិការ និង ០១ រូប មានឋានៈស្មើ អគ្គនាយក ៩៩៦៤

១៩.១២.២០១២ -ព្រះរាជក្រឹត្យ នស/រកត/១២១២/១០៥៩ ស្តីពី ការផ្ទេរ និង ប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ចំនួន ០២ រូប នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ៩៩៦៥

១៩.១២.២០១២ -ព្រះរាជក្រឹត្យ នស/រកត/១២១២/១០៦០ ស្តីពី ការដំឡើងឋានន្តរស័ក្តិ ដល់នាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ចំនួន ០៤ រូប ៩៩៦៦

១៩.១២.២០១២ -ព្រះរាជក្រឹត្យ នស/រកត/១២១២/១០៦១ ស្តីពី ការដំឡើងឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈ ជូនសពនាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ចំនួន ០៤ រូប ៩៩៦៧

១៩.១២.២០១២ -ព្រះរាជក្រឹត្យ នស/រកត/១២១២/១០៦២ ស្តីពី ការតែងតាំងជាទីប្រឹក្សាក្រសួងមហាផ្ទៃ ចំនួន ០២ រូប ៩៩៦៨

II. រាជរដ្ឋាភិបាល

អនុក្រឹត្យ

១៣.១២.២០១២-អនុក្រឹត្យលេខ ២៥០ អនក្រ.បក ស្តីពី ការផ្ទេរគណទានថវិកា ៩៩៦៩

១៣.១២.២០១២-អនុក្រឹត្យលេខ ២៥១ អនក្រ.បក ស្តីពី ការកាត់ដីសរុបទំហំ ៤.៤១៨,៤៦ ហិកតា នៅស្រុកវាលវែង ខេត្តពោធិ៍សាត់ ពីដែនជម្រកសត្វព្រៃភ្នំសំកុស នៃព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ និង ធ្វើ អនុបយោគជាដីឯកជនរបស់រដ្ឋ និង ពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន អ៊ីមឌីអេស នីហ្វ័រណេដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិ ជូនប្រជាពលរដ្ឋ និង រក្សាទុកសម្រាប់កំណើនប្រជាពលរដ្ឋ និង ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និង ការ ផ្តល់សិទ្ធិលើក្បាលដី ៩៩៧១

p

គ

១៣-១២-២០១២-អនុក្រឹត្យលេខ ២៥២ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ទីតាំងដីបឹងពោងពាយ ខាងជើង ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ទៅជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ៩៩៧៨

១៥-១២-២០១២-អនុក្រឹត្យលេខ ២៥៣ អនក្រ.បក ស្តីពី ការកាត់ដីសរុបទំហំ ៣.៥៥៣ ហិកតា នៅស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង ពីព្រៃសម្បទាន ក្រុមហ៊ុន PHEAPIMEX FUCHAN CAMBODIA Co., LTD និង ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និង ការផ្តល់សិទ្ធិលើក្បាលដី ៩៩៨២

១៧-១២-២០១២-អនុក្រឹត្យលេខ ២៥៤ អនក្រ.បក ស្តីពី ការបំពេញបន្ថែមលើអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ ២០០៤ ស្តីពី ការបំពេញបន្ថែមលើ អនុក្រឹត្យលេខ ១១៥ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ ១៩៩៩ ស្តីពីការបង្កើត សាកលវិទ្យាល័យភូមិន្ទកសិកម្ម ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ៩៩៨៥

០២-១១-២០១២-អនុក្រឹត្យលេខ **២២២៩** ដល់អនុក្រឹត្យលេខ **២២៨៣** អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៩៩៨៨

III-ការងារបណ្តាក្រសួង

ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

២៦-៧-២០១១ -លិខិតបញ្ជាក់លេខ ៤៣៦៨ ពណ.ចបព ស្តីពី ការទទួលចុះបញ្ជីនូវការបង្កើតសាខាក្រុមហ៊ុន **ស៊ីរ៉ម្មីនី គ្រេនស្ព័រថេសិន & ខនស្ត្រាក់សិន " សៀមរាប "** ១០០៤៣

២៦-៧-២០១១ -លិខិតបញ្ជាក់លេខ ៤៣៧៤ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **គ្រីស្តាល់ អ៊ិនជាសស្ត្រៀល (កម្ពុជា)** ១០០៤៤

២៦-៧-២០១១ -លិខិតបញ្ជាក់លេខ ៤៣៧៥ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **គ្រីស្តាល់ "រ៉ាយស៍" (កម្ពុជា)** ១០០៤៦

២៦-៧-២០១១ -លិខិតបញ្ជាក់លេខ ៤៣៧៦ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ការិយាល័យតំណាងពាណិជ្ជកម្មក្រុមហ៊ុន **ធ្រីណឺធី ស្ត្រាត់ឈឺរ & ហ្វាយនែន លីមីធីត** ១០០៤៨

២៦-៧-២០១១ -លិខិតបញ្ជាក់លេខ ៤៣៨៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ឌីរៈ ជាយ័ន** ១០០៤៩

២៦-៧-២០១១ -លិខិតបញ្ជាក់លេខ ៤៣៨៤ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ព្រីម៉ារីឆែលស៍ អ៊ិនវេសមេន លីមីធីត** ១០០៥១

p

២៦-៧-២០១១ -លិខិតបញ្ជាក់លេខ ៤៣៨៥ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ចាន់ សុខា អ៊ីមផត អិចផត & សឺវីស** ១០០៥៣

២៦-៧-២០១១ -លិខិតបញ្ជាក់លេខ ៤៣៨៦ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ខេ-យ៉ត ត្រាវែល សឺវីស** ១០០៥៥

២៧-៧-២០១១ -លិខិតបញ្ជាក់លេខ ៤៣៨៧ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ឆាយណា ម៉ាន់ហ្គាត គ្រុប (ខេមបូឌា) ខូ អិលធីឌី** ១០០៥៧

២៧-៧-២០១១ -លិខិតបញ្ជាក់លេខ ៤៣៨៨ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **សេវេនទ្រី ខ្មែរ រ៉ាយស៍** ១០០៥៩

២៧-៧-២០១១ -លិខិតបញ្ជាក់លេខ ៤៣៨៩ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេ.អេច.អេស.ធី. អ៊ីមផត អិចផត** ១០០៦១

២៧-៧-២០១១ -លិខិតបញ្ជាក់លេខ ៤៣៩០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេ.ឌី.អ ស៊ីឃ្យួរីធី** ១០០៦៣

២៧-៧-២០១១ -លិខិតបញ្ជាក់លេខ ៤៣៩១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **យឹម សុខលី គ្រុប (ម៉ាយ.អេស.អិល.ជី.)** ១០០៦៥

បញ្ជាក់: *ព្រះរាជក្រម.ព្រះរាជក្រឹត្យ.អនុក្រឹត្យ ឆ្នាំ ២០១២ នឹងមានចុះផ្សាយក្នុងរាជកិច្ចដើមឆ្នាំ ២០១៣ បន្តទៀត ។*

ព្រះរាជក្រឹត្យ

នស/រកត/១២១២/១០៤៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ទោ** ជូនលោកឧត្តមសេនីយ៍ត្រី **សត ណាឌី** អត្តលេខ ០១០៦ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

រកត.១២១២.១០៤៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១២

លេខ ...១០១៥ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ២០១២
...ទីស្តីការគណៈរដ្ឋមន្ត្រី
... សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/១២១២/១០៥៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពុហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៖

១- លោកវរសេនីយ៍ឯក	**ឆៃលី សុវឌ្ឍនា**	អត្តលេខ	០១៨១
២- លោកវរសេនីយ៍ឯក	**ស៊ី គីរី**	អត្តលេខ	០៤៧២
៣- លោកវរសេនីយ៍ឯក	**ពេជ្រ វីរៈ**	អត្តលេខ	០៨៥១៥
៤- លោកវរសេនីយ៍ឯក	**គួច ម៉ាល័យ**	អត្តលេខ	០៦៨៥
៥- លោកវរសេនីយ៍ឯក	**ហ៊ី ព្រូ**	អត្តលេខ	០៦៨៨
៦- លោកវរសេនីយ៍ឯក	**អែល សំណាង**	អត្តលេខ	០១៥០៩
៧- លោកស្រីវរសេនីយ៍ឯក	**សន សុផល**	អត្តលេខ	០៩៧៣៨ ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

រ.ក.ម. ១៤១២. ១០៥៥

បានយកសេចក្តីក្រាបបង្គំទូល
ថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
នាយករដ្ឋមន្ត្រី
ហត្ថលេខា

រាជធានីភ្នំពេញ ថ្ងៃទី ខែ ធ្នូ ឆ្នាំ២០១២

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១២

p

ព្រះរាជក្រឹត្យ

នស/រកត/១២១២/១០៤៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជូនលោកវរសេនីយ៍ឯក **គីម យន** អត្តលេខ ១០៧០១ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពាក. ១៤១៤_១០៤៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២

ដើម្បីចម្លងចែក
ឆ្នាំ២០១២
រាជរដ្ឋាភិបាល
សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/១២១២/១០៤៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ថ្នាក់ដឹកនាំនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងដៃគូសហប្រតិបត្តិការ ចំនួន ១៧រូប ដែលមានស្នាដៃល្អក្នុងការ អនុវត្តគម្រោងកម្មវិធីលើវិស័យពិការភាព នៅព្រះរាជាណាចក្រកម្ពុជា

នូវ

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍

១- ឯកឧត្តម ស៊ឹង ម៉ុន
២- លោក សៀង សុខឃុនធី
៣- ឯកឧត្តម ប្រាក់ ចាន់ធឿន
៤- លោក អៀម យាង
៥- លោក តូច ចាន់នី

ខ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍

១- ឯកឧត្តម គ្រួច សុផារី
២- លោក លឹម អេឈម្យូរ៉ាំងូ
៣- លោក ញៀម ចាន់ណេង
៤- លោក គឹម ហុង
៥- លោក គឹម រតនា

គ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

១- ឯកឧត្តម ជុំ សៀកឌួន
២- លោក ឃួន ឧក្រានិច
៣- លោក មាស ឈាន
៤- លោក ហួត សារិកល
៥- លោក ហែម ប៊ូរ៉ា
៦- លោក តុប សំអ៊ី
៧- លោក អ៊ុង គន្ធាថារ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

[illegible]-០៤១៤-១០៤៩

លេខ:១០៦៩ ច.ល
[illegible] ចែក
រាជ[illegible] ធ្នូ ឆ្នាំ២០១២
[illegible] រាជរដ្ឋាភិបាល
[illegible] សុខា

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១២

p

ព្រះរាជក្រឹត្យ

នស/រកត/១២១២/១០៥០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ថ្នាក់ដឹកនាំ និងមន្ត្រីនិយោជិតនៃកំពង់ផែស្វយ័តភ្នំពេញ ចំនួន ៣២រូប មានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិកន្លងមក សម្រេចបានលទ្ធផលល្អប្រសើរ

ជូន

ក-គ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រិយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរ័ត្ន ថ្នាក់ មហាសេរីវឌ្ឍន៍

១- ឯកឧត្តម លី ស៊ីវណ្ណា
២- ឯកឧត្តម មាស ឫទ្ធី
៣- លោក ទឹម គឹមពិសិដ្ឋ
៤- លោកស្រី គឹម សែន
៥- លោក ជៀប ឌុយ
៦- លោក អៀង ចេងស៊ុន
៧- លោក អាន សំអុល
៨- លោក ម៉ម រិទ្ធី

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍

១- លោក សុខ គឹមសោភ
២- លោក ហ៊ីង ពុទ្ធីរិទ្ធ
៣- លោក ឌុម សុវណ្ណ

គ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍

- ឯកឧត្តម កែន សម្បត្តិ

ឃ-គ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រិយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរ័ត្ន ថ្នាក់ មហាសេនា

១- លោក ណែម ឌីម
២- លោក គុយ ប៊ុនឆន
៣- លោក ចៀក តិរុណន
៤- លោកស្រី ហ៊ុំ សារិន
៥- លោក យឹម ជឿន
៦- លោក ព្រុំ សុខានី
៧- លោក ជី ចិត្រា

ង-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា

១- លោកស្រី ជួន សុខេម
២- លោក ឈឹម សុខគាំង
៣- លោក គង់ សុធា
៤- លោក គង់ ជួន
៥- លោក ឌី ប្រុង

ច-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន

- លោក ចេង ណាន

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

ង-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា

១- លោក ច្រាក់ សាមិត្ត
២- លោក ម៉ៅ ស៊ីណាត
៣- លោកស្រី ស៊ុន តារា
៤- លោកស្រី ច្រាក់ មិន្តា
៥- លោក អ៊ឹង ឆាយឌួន
៦- លោក ម៉ែន ឈុំ
៧- លោក លីម សុទ្ធិបុល

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

[illegible]

លេខ:១០០៧ប.ល

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ២០១២

[illegible] ចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ២០១២
[illegible] រាជរដ្ឋាភិបាល

[illegible] សុខា

ព្រះរាជក្រឹត្យ

នស/រកត/១២១២/១០៥១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ប្រធាន និងអនុប្រធានទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ(KOICA) ប្រចាំព្រះរាជាណាចក្រកម្ពុជា និងនាយកប្រតិបត្តិនៃក្រុមហ៊ុន Korea Expressway Corporation ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការសាងសង់ផ្លូវមិត្តភាពកម្ពុជា-កូរ៉េ (ផ្លូវរាងតំបន់មេឈើយដ្ឋានអង្គរ) ជំហានទី២ នូវ

ក-គ្រឿងឥស្សរិយយស សហាមេត្រី ថ្នាក់ មហាសេរីវឌ្ឍន៍ះ

បណ្ឌិត Shin Eui-Cheol

ខ-គ្រឿងឥស្សរិយយស សហាមេត្រី ថ្នាក់ មហាសេនា

១- លោក Shin Myung-Seop

២- លោក Kim Nak-Joo

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ការ.១៤១៤-២០១១

លេខ: ២០០០ ប.ល

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១២

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ធ្នូ ឆ្នាំ២០១២

...រដ្ឋាភិបាល

សយ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/១២១២/១០៥៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២០៩/១៧៣ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពីការបង្កើតក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **សេង ហួរលាង** ជាសមាជិកអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ មានឋានៈស្មើ រដ្ឋលេខាធិការ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខា តទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣ល: ១២១២-១០៥៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២

[illegible] ច.ល
[illegible]
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១២
[illegible] រដ្ឋាភិបាល
[illegible] សុខា

ព្រះរាជក្រឹត្យ

នស/រកត/១២១២/១០៥៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ទោ** ជូនលោកឧត្តមសេនីយ៍ត្រី **ម៉ិញ សុធីចណ្ណា** អត្តលេខ ០៧០២ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ច.ល
ឆ្នាំ២០១២

ការ: ១២១២-១០៥៣

សុខា

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២

p

ព្រះរាជក្រឹត្យ

នស/រកត/១២១២/១០៥៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រទានព្រះរាជទាន

ចំពោះ

នាយនគរបាលជាតិជាន់ខ្ពស់ចំនួន ១១២ រូប នៃក្រសួងមហាផ្ទៃ ដែលបានខិតខំប្រឹងប្រែងបំពេញភារកិច្ចថែរក្សា ការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាព និងស្ថេរភាពសង្គម ដើម្បីបំពីផលប្រយោជន៍របស់ប្រទេសជាតិ និងប្រជាពលរដ្ឋបានល្អប្រសើរ

នូវ

ក-គ្រឿងឥស្សរិយយស ការពារជាតិ ថ្នាក់មាស ០២ គ្រឿង ប្រាក់ ០២ គ្រឿង សំរិទ្ធ ០២ គ្រឿង :

- លោកឧត្តមសេនីយ៍ត្រី ចឹន្ទ សាម៉ន អត្តលេខ ៦៤២៨៣

ខ-គ្រឿងឥស្សរិយយស ការពារជាតិ ថ្នាក់មាស ០១ គ្រឿង ប្រាក់ ០១ គ្រឿង សំរិទ្ធ ០១ គ្រឿង :

១- លោកឧត្តមសេនីយ៍ត្រី ជា យោធិន អត្តលេខ ០៣៩២៥
២- លោកឧត្តមសេនីយ៍ត្រី មែ ស៊ីខេងហ៊ាន់ទី អត្តលេខ ៦២៧២២
៣- លោកឧត្តមសេនីយ៍ត្រី ប៊ុល សុខនាង អត្តលេខ ០៦១៣១
៤- លោកឧត្តមសេនីយ៍ត្រី ប៉ាវ គីមហេង អត្តលេខ ០៣៧២
៥- លោកឧត្តមសេនីយ៍ត្រី ប៉ោ ហាក់យង់ អត្តលេខ ០១០៧១
៦- លោកឧត្តមសេនីយ៍ត្រី គិន រោជ អត្តលេខ ០៥១៥៨
៧- លោកឧត្តមសេនីយ៍ត្រី រ៉ាន់ ចន្ទី អត្តលេខ ០៥១០៤
៨- លោកឧត្តមសេនីយ៍ត្រី គង់ សុជាតិ អត្តលេខ ០១៥០៣
៩- លោកឧត្តមសេនីយ៍ត្រី ឆឿន សុភ័ក្រ្តា អត្តលេខ ៦៤៣៦១

១៧- លោកឧត្តមសេនីយ៍ត្រី ផាង សុវណ្ណារិទ្ធ អត្តលេខ ៥៤៨៣១
១៨- លោកវរសេនីយ៍ឯក ខាត់ សាត អត្តលេខ ៦៨២៨៨
១៩- លោកវរសេនីយ៍ទោ ប៊ិន មណីរង្ស៊ី អត្តលេខ ៦៨៣២៩
២០- លោកវរសេនីយ៍ទោ អ៊ុន សុវណ្ណាសារ អត្តលេខ ៦៨៣២៨
២១- លោកវរសេនីយ៍ទោ សុខ គឹមស៊ីន អត្តលេខ ៦៨៣២៧
២២- លោកវរសេនីយ៍ទោ ញូង សារ៉ែន អត្តលេខ ៣២០៩២
២៣- លោកវរសេនីយ៍ទោ អេម សំអាល់ អត្តលេខ ៥៧០៦៣
២៤- លោកវរសេនីយ៍ទោ ហេង រង្សី អត្តលេខ ៥៧០៦៣
២៥- លោកវរសេនីយ៍ទោ កង ភូមិន្ទ អត្តលេខ ៥៨១២៥
២៦- លោកវរសេនីយ៍ត្រី ហាស់ វីណា អត្តលេខ ៦៧៨៩២
២៧- លោកវរសេនីយ៍ត្រី ជួង សុភា អត្តលេខ ៦៨៣៦៨
២៨- លោកស្រីវរសេនីយ៍ត្រី ហោង លីច្ចនិកា អត្តលេខ ៥៥៧៣៨
២៩- លោកវរសេនីយ៍ត្រី ឯម លីដា អត្តលេខ ៥៩៥៤៤
៣០- លោកវរសេនីយ៍ត្រី ឈុន ប៊ុនហៀង អត្តលេខ ៣១៨៥០
៣១- លោកវរសេនីយ៍ត្រី ហង់ គីរម្យ អត្តលេខ ១៣០៨៤
៣២- លោកវរសេនីយ៍ត្រី ពួ ឫទ្ធី អត្តលេខ ៥៥០១៧
៣៣- លោកវរសេនីយ៍ត្រី សារី ខ្សែនា អត្តលេខ ៥៥៣៦៩
៣៤- លោកវរសេនីយ៍ត្រី ស៊ីម ចាន់នី អត្តលេខ ៦២៨៥៨
៣៥- លោកវរសេនីយ៍ត្រី គី គេនណោគនា អត្តលេខ ៦៤៣៥៦
៣៦- លោកវរសេនីយ៍ត្រី មាស ម៉ារិន អត្តលេខ ០៤៩៩៨
៣៧- លោកវរសេនីយ៍ត្រី ឈា ស៊ីញ៉ិល អត្តលេខ ៥៧២៥៧
៣៨- លោកវរសេនីយ៍ត្រី ពេជ រិទ្ធី អត្តលេខ ៦២១២២
៣៩- លោកវរសេនីយ៍ត្រី គង់ សាធឿន អត្តលេខ ០៥៦០៥
៤០- លោកវរសេនីយ៍ត្រី ផាន់ សុភាព អត្តលេខ ០៥៦៣៣
៤១- លោកវរសេនីយ៍ត្រី អ៊ូម សុវណ្ណា អត្តលេខ ០៥៦២៧
៤២- លោកវរសេនីយ៍ត្រី ចាន់ ធោម អត្តលេខ ០៥៦២៤
៤៣- លោកវរសេនីយ៍ត្រី ប៉ែន តាត អត្តលេខ ៣៣១១៤
៤៤- លោកវរសេនីយ៍ត្រី ជៀវ ចំនួបូរ៉ា អត្តលេខ ៥៦៥០៦
៤៥- លោកវរសេនីយ៍ត្រី សុង ពៅ អត្តលេខ ០៧១៧៧
៤៦- លោកស្រីវរសេនីយ៍ត្រី តាន់ យ៉ិនណា អត្តលេខ ០៦៦៦០
៤៧- លោកវរសេនីយ៍ត្រី ម៉ែន ភារម្យ អត្តលេខ ១២៩៦៥
៤៨- លោកស្រីវរសេនីយ៍ត្រី អ៊ុន តេនា អត្តលេខ ៥៥១៩៧
៤៩- លោកវរសេនីយ៍ត្រី សុខ អាន អត្តលេខ ៣១២៨៤
៥០- លោកវរសេនីយ៍ត្រី នូវ វិណា អត្តលេខ ០៦៦៥២
៥១- លោកវរសេនីយ៍ត្រី ហែម ប៊ុនធឿន អត្តលេខ ១៦២១០
៥២- លោកវរសេនីយ៍ត្រី ញ៉ិក វិសាល អត្តលេខ ៥៥២៤៧

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

៥៣- លោកវរសេនីយ៍ត្រី	ហេង	សុវណ្ណ	អត្តលេខ ០៦៩៩៨
៥៤- លោកវរសេនីយ៍ត្រី	អ៊ី	ចាន់ណារ៉ា	អត្តលេខ ០៥១៥៦
៥៥- លោកវរសេនីយ៍ត្រី	អ៊ុក	គីមហេង	អត្តលេខ ០៥១៦៤
៥៦- លោកវរសេនីយ៍ត្រី	ភិ	សុវណ្ណរ៉ា	អត្តលេខ ០៥១៤៥
៥៧- លោកវរសេនីយ៍ត្រី	ឈឹម	បុណ្ណា	អត្តលេខ ០៥១៤៩
៥៨- លោកវរសេនីយ៍ត្រី	ឯម	សុគន្ធី	អត្តលេខ ០៥១៥៣
៥៩- លោកវរសេនីយ៍ត្រី	យឹម	លី	អត្តលេខ ០៦៥៤៨
៦០- លោកវរសេនីយ៍ត្រី	ចាន់	គីមឡេង	អត្តលេខ ៣៧១៥២
៦១- លោកវរសេនីយ៍ត្រី	ជិន	ខាំផេង	អត្តលេខ ៦៨៣២៦
៦២- លោកវរសេនីយ៍ត្រី	ឡុង	សង្ហា	អត្តលេខ ៦៨២១៩
៦៣- លោកវរសេនីយ៍ត្រី	សុង	វីជេត	អត្តលេខ ៦៨២១៨
៦៤- លោកវរសេនីយ៍ត្រី	គិន	ឧត្តម	អត្តលេខ ៦៨៣១៧
៦៥- លោកវរសេនីយ៍ត្រី	តែ	ជិនវង្សា	អត្តលេខ ៦៨៣១៦
៦៦- លោកវរសេនីយ៍ត្រី	ខាន់	លីណា	អត្តលេខ ៥៤២៥៧
៦៧- លោកវរសេនីយ៍ត្រី	ឈឹម	សុវត្ថា	អត្តលេខ ៦២៥៦៧
៦៨- លោកវរសេនីយ៍ត្រី	ឈុន	លាងគិច	អត្តលេខ ៣៧១៤៧
៦៩- លោកស្រីវរសេនីយ៍ត្រី	ព្រាប	ស៊ុននីម៉ត	អត្តលេខ ០៦៤៥៤
៧០- លោកវរសេនីយ៍ត្រី	មួង	រិទ្ធី	អត្តលេខ ៥៦៥៩៨
៧១- លោកវរសេនីយ៍ត្រី	ធម្ម	ច័ន្ទពុទ្ធិកា	អត្តលេខ ៥៤២៩៣
៧២- លោកវរសេនីយ៍ត្រី	ជុំ	សំអឿន	អត្តលេខ ០១៥០៤
៧៣- លោកស្រីវរសេនីយ៍ត្រី	សំ	ច័ន្ទធា	អត្តលេខ ៦៤៣០៣
៧៤- លោកវរសេនីយ៍ត្រី	យី	គីមឡោ	អត្តលេខ ៥៤៧៩០
៧៥- លោកវរសេនីយ៍ត្រី	ឈាង	សុខារ៉ា	អត្តលេខ ៥៥២៩៦
៧៦- លោកវរសេនីយ៍ត្រី	វិឡូនៈ	មង្គល	អត្តលេខ ៥៧៨៧២
៧៧- លោកវរសេនីយ៍ត្រី	លឹម	ហុងសេង	អត្តលេខ ៥៦៦០២
៧៨- លោកវរសេនីយ៍ត្រី	ភឿន	ភិរុណ	អត្តលេខ ៦៤៣៦៣
៧៩- លោកវរសេនីយ៍ត្រី	ឡេង	ចាន់ស្មើ	អត្តលេខ ៦៤៤០២
៨០- លោកវរសេនីយ៍ត្រី	សុខ	សុមនោ	អត្តលេខ ៥៣៨១២
៨១- លោកវរសេនីយ៍ត្រី	រស់	សារឿន	អត្តលេខ ៦៣១៨៦
៨២- លោកវរសេនីយ៍ត្រី	ឈយ	សាម៉េត	អត្តលេខ ០៦៤៥២
៨៣- លោកវរសេនីយ៍ត្រី	ថ្លាង	ម៉ាលីយ	អត្តលេខ ០៦៤៦៨
៨៤- លោកវរសេនីយ៍ត្រី	សៀក	ហុក	អត្តលេខ ០៦៤៦៤
៨៥- លោកវរសេនីយ៍ត្រី	សៅ	ចាន់ថន	អត្តលេខ ០៦៩៩៥
៨៦- លោកវរសេនីយ៍ត្រី	ផុន	ណារី	អត្តលេខ ០៦៩៨២
៨៧- លោកវរសេនីយ៍ត្រី	ខេត	ខេមន្ទ	អត្តលេខ ០៦៩៩០
៨៨- លោកវរសេនីយ៍ត្រី	អ៊ុំ	ផាលីន	អត្តលេខ ៣១១០៨

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

p

៨៩- លោកវរសេនីយ៍ត្រី	ហុង	ឡារី	អត្តលេខ ០៦៩៨៥
៩០- លោកវរសេនីយ៍ត្រី	សារី	វិឃ្លនៈ	អត្តលេខ ៦២១២៣
៩១- លោកវរសេនីយ៍ត្រី	គឹម	សារ៉េន	អត្តលេខ ០៦៤៩៦
៩២- លោកវរសេនីយ៍ត្រី	ពុទ្ធ	ស៊ីវ៉ាន់	អត្តលេខ ០៦៤៦៥
៩៣- លោកវរសេនីយ៍ត្រី	សយ	សុផាន្នី	អត្តលេខ ១២៣១១
៩៤- លោកវរសេនីយ៍ត្រី	រស់	រិទ្ធី	អត្តលេខ ០៧០១៣
៩៥- លោកវរសេនីយ៍ត្រី	លី	សុខា	អត្តលេខ ០៧០០៥
៩៦- លោកវរសេនីយ៍ត្រី	អ៊ុំ	ម៉ានី	អត្តលេខ ៣១៥៧៩
៩៧- លោកវរសេនីយ៍ត្រី	ជុំ	ពៅ	អត្តលេខ ០៧០០៨
៩៨- លោកវរសេនីយ៍ត្រី	លឹម	សុផល	អត្តលេខ ០៦៩៦៣
៩៩- លោកវរសេនីយ៍ត្រី	ហោ	ស៊ិនហ៊ន	អត្តលេខ ០៧០១៦
១០០- លោកវរសេនីយ៍ត្រី	អៀង	ជៀង	អត្តលេខ ០៦៩៩៦
១០១- លោកវរសេនីយ៍ត្រី	នាក់	រិន	អត្តលេខ ០៦៩៤៥
១០២- លោកវរសេនីយ៍ត្រី	តូ	រិទ្ធី	អត្តលេខ ៣១១៩៨
១០៣- លោកវរសេនីយ៍ត្រី	រស់	សុខេន	អត្តលេខ ០៧០០១
១០៤- លោកវរសេនីយ៍ត្រី	សៅ	ហេង	អត្តលេខ ៣១១២២
១០៥- លោកវរសេនីយ៍ត្រី	ហ៊ាន	សុផល	អត្តលេខ ៣១១៨២
១០៦- លោកវរសេនីយ៍ត្រី	ជូ	សៅណាល	អត្តលេខ ៣១១៩៤
១០៧- លោកវរសេនីយ៍ត្រី	កុន	ផល	អត្តលេខ ០៦៩៣៩
១០៨- លោកវរសេនីយ៍ត្រី	ឈុន	សំអុល	អត្តលេខ ០៦៩៤៩
១០៩- លោកវរសេនីយ៍ត្រី	ឈៀង	ទិត្យ	អត្តលេខ ០៦៩៥១
១១០- លោកវរសេនីយ៍ត្រី	អ៊ុំ	សារឿន	អត្តលេខ ៣១១១៧
១១១- លោកវរសេនីយ៍ត្រី	អ៊ឹម	ប៉េត	អត្តលេខ ១៦២២៣

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

[illegible]

លេខ:១០០ ៥ច.ល

[illegible] ចម្លងចែក

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១២

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១២

[illegible] ទីស្តីការគណៈរដ្ឋមន្ត្រី

[illegible] សុខា

ព្រះរាជក្រឹត្យ

នស/រកត/១២១២/១០៥៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

អស់លោក ចំនួន៥០រូប ដែលបានខិតខំប្រឹងប្រែង បំពេញភារកិច្ចបានល្អប្រសើរ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល

នូវ

ក- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសិរីវឌ្ឍន៍** :

១-លោក **ទាន់ សុធា**
២--លោក **អ៊ុំ វណ្ណារិន**
៣-លោក **ហាច សុផាណារ៉ា**
៤-លោក **អ៊ូច ចន្ធី**

ខ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** :

១-លោក **អ៊ឹង ប៊ុនសុវណ្ណ**
២-លោក **ម៉ឹង ឌុធី**
៣-លោក **ពឹង គមហួរ**
៤-លោក **ជា សំបូរណ៍**
៥-លោក **ប៊ុន ណារុំ**
៦-លោក **សាយ ម៉េងឈាង**

គ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា**:

១-លោក **ធីច ប៉ាឌុល្ល**
២-លោក **យស់ ផរះ**
៣-លោក **ស្រ៊ី រតនៈ**
៤-លោក **ផាន់ វណ្ណារ័ត្ន**
៥-លោក **ណុប សម្បត្តិ**
៦-លោក **យ៉យ ឈួន**
៧-លោក **សាត គឹមសាន**

ឃ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ**៖

១-លោក **ហោ ធាសណា**
២-លោក **ម៉េង ឡូញ**
៣-លោក **សុខ ហួត**
៤-លោក **គង់ ហ៊ាន**
១៨-លោក **ហោ ញ៉េប**
១៩- លោក **ហួន សម្បត្តិ**
២០-លោក **ឡេង សាធុជ**
២១-លោក **ម៉ិច ភារារិទ្ធ**

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

៥-លោក **យ៉ាន បុផៃ**
៦-លោក **ចែត ចន្ទ្រះ**
៧-លោក **អ៊ិត សុធា**
៨-លោក **មូល សារឿន**
៩-លោក **ធូច ស្វាង**
១០-លោក **មេន សំអាត**
១១-លោក **តាន់ ថេត**
១២-លោក **ប៉ាវ ហេងតារា**
១៣-លោក **ជា សំបូរ**
១៤-លោក **ជួន សំណាង**
១៥-លោក **ឡុង ស៊ីវ៉ាឌុធ**
១៦-លោក **តម ច័ន្ទរស្មី**
១៧-លោក **ប៉ុន សុធារ៉ូ**
២២-លោក **ជា សំណាង**
២៣-លោក **លី ខែងសេ**
២៤-លោក **ស៊ីម សារីធន**
២៥-លោក **ប៉ាន ឆានី**
២៦-លោក **ចេង សុខណាត**
២៧-លោក **ខ៉ាន់ ឌុស្សី**
២៨-លោក **ឌិន សុភាព**
២៩-លោក **ជិម រតនា**
៣០-លោក **សួង រ៉ា**
៣១-លោក **ឌិន សុភាព**
៣២-លោក **ស៊ុន ដារ៉ាច័ន្ទ**
៣៣-លោក **ឆៃ ចណ្ណះ**

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

នស/រកត/១២១២/១០៦៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២

លេខៈ ១០០៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ២០១២
អគ្គលេខាធិការរងនៃរាជរដ្ឋាភិបាល
សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/១២១២/១០៥៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រត្តនខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ជាតូបការ

ចំពោះ

ឧកញ៉ា ខួច សម្បត្តិ

ដែលបានចំណាយពេលវេលា ព្រមទាំងទ្រព្យសម្បត្តិផ្ទាល់ខ្លួន ចូលរួមចំណែក
យ៉ាងសកម្មក្នុងការងាររក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈក្នុងបុព្វហេតុកសាងជាតិ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពសល-៤២១២-១០៥៦

លេខៈ ៩៩៩ ច.ល
ដើម្បីចម្លងចែក

ធ្វើនៅព្រះបរមរាជវាំង.ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១២

រាជធានីភ្នំពេញ ថ្ងៃទី ... ឆ្នាំ២០១២
...រដ្ឋាភិបាល
... សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/១២១២/១០៥៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យលរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យលព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ដំឡើងឋានន្តរស័ក្តិពីវរមន្ត្រីទៅឧត្តមមន្ត្រីជូនមន្ត្រីរាជការ ៤រូប នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ៖

ល.រ	នាម-គោត្តនាម	ភេទ	ថ្ងៃ ខែ ឆ្នាំកំណើត	មុខតំណែង	ក្របខណ្ឌឋានន្តរស័ក្តិ និងថ្នាក់	
					ចាស់	ស្នើសុំ
១	ធុល នាង	ប	១៥ / ធ្នូ / ១៩៦៨	ប្រធានមន្ទីរ	វរៈមន្ត្រី ថ្នាក់លេខ ៧	ឧត្តមមន្ត្រី ថ្នាក់លេខ៦
២	ណាយ ស្រេន	ប	១៥ / មីនា / ១៩៦០	ប្រធានមន្ទីរ	វរៈមន្ត្រី ថ្នាក់លេខ ៧	ឧត្តមមន្ត្រី ថ្នាក់លេខ៦
៣	ឡុង សាវណ្ណ	ប	១៤ / មេសា / ១៩៥៣	ប្រធានមន្ទីរ	វរៈមន្ត្រី ថ្នាក់លេខ ៧	ឧត្តមមន្ត្រី ថ្នាក់លេខ៦
៤	ភួង ជា	ប	១០ / កញ្ញា / ១៩៦៩	ប្រធានមន្ទីរ	វរៈមន្ត្រី ថ្នាក់លេខ ៧	ឧត្តមមន្ត្រី ថ្នាក់លេខ៦

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៦ល. ១២.១២.១០៥៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១២

លេខៈ ១៦៤៦ ប.ល

ចម្លងចេញពីច្បាប់ដើម

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០១២

[illegible] រដ្ឋាភិបាល

[illegible] សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/១២១២/១០៥៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំង៖

១-ឯកឧត្តម **ហ៊ូ ឌុន្ណី** ជាទីប្រឹក្សាអមក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈមានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

២-ឯកឧត្តម **ហឿង សុផុន** ជាទីប្រឹក្សាអមក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈមានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

៣-ឯកឧត្តម **ផេង សុខាំ** ជាទីប្រឹក្សាអមក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈមានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

៤-ឯកឧត្តម **ឡាយ ម៉េងលី** ជាទីប្រឹក្សាអមក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈមានឋានៈស្មើ **អគ្គនាយក** ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស.១៧.១២.១០៥៧

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១២

លេខៈ ... ច.ល

... ជូន ...

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០១២

... រដ្ឋាភិបាល

... សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/១២១២/១០៥៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យលព្រះរាជក្រម លេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្ទេរ និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការចំនួន ០២ រូប នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖

១- ឯកឧត្តម **សំហេង បុរស** ឱ្យបំពេញមុខងារជាអគ្គនាយក នៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ ជំនួសឯកឧត្តម **ទៀង សុគន្ធ** ដែលត្រូវបានដាក់ឲ្យចូលនិវត្តន៍

២- ឯកឧត្តម **គីម ហុង** ឱ្យបំពេញមុខងារជាអគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកទេស ជំនួសឯកឧត្តម **ប្រាក់ ចាន់ធឿន** ដែលត្រូវបានទទួលភារកិច្ចថ្មី ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យ បានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

រ.ក.ត. ១២.១២.១០៥៩

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១២

លេខ ១០[illegible] ២ ប.ល
ដើម្បីចម្លងចែកជូន
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១២
អគ្គលេខាធិការរាជរដ្ឋាភិបាល
[illegible] សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/១២១២/១០៦០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ដំឡើងឋានន្តរសក្តិ ដល់ នាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ៖

ក-ដំឡើងឋានន្តរសក្តិថ្នាក់ឧត្តមសេនីយ៍ទោ

- ឧត្តមសេនីយ៍ត្រី **ឈុន** **ឆេង** អត្តលេខ ០០៣៥៩៨

ខ-ដំឡើងឋានន្តរសក្តិថ្នាក់ឧត្តមសេនីយ៍ត្រី

១-វរសេនីយ៍ឯក **ឡុង** **ណាម** អត្តលេខ ០០២៨១២
២-វរសេនីយ៍ឯក **ឈើង** **សារុន** អត្តលេខ ០០២៨៨៣
៣-វរសេនីយ៍ឯក **ពៅ** **សំរេត** អត្តលេខ ០០៤៩៥៧

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចរស. ១២១២.១០៧០

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១២

ឆ្នាំ២០១២
... រដ្ឋាភិបាល
... សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/១២១២/១០៦១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសំរួលភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ដំឡើងឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈ ជូនសពនាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ

ក. ដំឡើងឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ទោ

- ឧត្តមសេនីយ៍ត្រី **សុខ្ន មុណ្យនិត្យ** អត្តលេខ ០០៣០០២

ខ. ដំឡើងឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ត្រី

១- វរសេនីយ៍ឯក **ឌុច ឈឿន** អត្តលេខ ០០៨៨៩២
២- វរសេនីយ៍ឯក **ឡុង ឿន** អត្តលេខ ០០៨៩៥៦
៣- វរសេនីយ៍ឯក **អេង ណារ៉ាន់** អត្តលេខ ០០៣១៨៩

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចារស. ១២១២. ១០៧២

ធ្វើនៅព្រះបរមរាជវាំង , ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១២

លេខ ១០[illegible]២ ប.ល
[illegible]
រាជ[illegible] ឆ្នាំ២០១២
[illegible]រដ្ឋាភិបាល
[illegible] សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/១២១២/១០៦៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រត្តតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងជាទីប្រឹក្សាក្រសួងមហាផ្ទៃ ចំនួន០២រូប ៖

១- ឯកឧត្តម **គង់ សំអឿន** មានឋានៈស្មើរដ្ឋលេខាធិការ ។

២- ឯកឧត្តម **គីម សារ៉ាន** មានឋានៈស្មើអនុរដ្ឋលេខាធិការ ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុក អនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ:១០៣៣ ប.ល
[illegible]ចែក
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ធ្នូ ឆ្នាំ២០១២
[illegible]រាជរដ្ឋាភិបាល
[illegible] សុខា

៣៧៧. ១៦.១២.១០៦៧

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១២

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៖ ២៥០.អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥, ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤, ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨, ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦, ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២១១/០១៩, ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០១២

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក, ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក, ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក, ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក, ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឲ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ២៨៧ អនក្រ.បក, ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១១ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០១២

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

p

សម្រេច

មាត្រា១: ត្រូវបានអនុញ្ញាតឲ្យផ្ទេរឥណទានថវិកាចំនួន៤ ៥៦៣ ០០០ ០០០រៀល(បួនពាន់ប្រាំរយហុកសិបបីលានរៀលគត់) ពីជំពូក០៩(ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក៦៥(ឧបត្ថម្ភធននិងជំនួយសង្គម) ជូនទីស្តីការគណៈរដ្ឋមន្ត្រីសម្រាប់ការគ្រប់គ្រងឆ្នាំ២០១២។

មាត្រា២: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីផ្តល់ជូនគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយទូទាត់ថវិកាបុរេប្រទានដែលបានចំណាយក្នុងឆ្នាំ២០១១។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

បានយកសេចក្តីជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ២៦១ អនក្រ-បក

អនុក្រឹត្យ
ស្តីពី
ការកាត់ដីសម្បទានទំហំ ៤ ៧១៨,៥៦ ហិកតា នៅស្រុកវាលវែង ខេត្តពោធិ៍សាត់ ពីដែនជម្រកសត្វព្រៃភ្នំសំកុស នៃព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ និងធ្វើអនុបយោគ ជាដីឯកជនរបស់រដ្ឋ និងពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុនអ៊ីមឌីអេសនីហាំងរ៉ា ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទុកសម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងការផ្តល់សិទ្ធិលើក្បាលដី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

p

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១២/១០៣៦ ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ២៩០៧ ខ.ពស ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តពោធិ៍សាត់
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១.

ត្រូវបានកាត់ផ្ទៃដីសរុបទំហំ ៤ ៩១៨,៨៦ ហិកតា ក្នុងនោះ ដីទំហំ ៤ ១០៧,៦៧ ហិកតា កាត់ចេញពីដែនជម្រកសត្វព្រៃភ្នំសំកុស តាមរយៈព្រះរាជក្រឹត្យកាត់ចេញពីព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ និងដីទំហំ **៣១០,៧៩ ហិកតា** ពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន អ៊ីមឌីអេសនីហ័រណេ ដើម្បីធ្វើប្រទានកម្មទំហំ **២.៩៧៧,៩៩ ហិកតា** ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ១ ៩៤០,៩៧ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅស្រុកវាលវែង ខេត្តពោធិ៍សាត់ ក្នុងភូមិឃុំ ដូចខាងក្រោម៖

១.១-ភូមិដីក្រហម ឃុំអន្លង់រាប

- ផ្ទៃដីទំហំ **២៧៩៦,៨៨ ហិកតា** កាត់ចេញពីដែនជម្រកសត្វព្រៃភ្នំសំកុស និងធ្វើអនុប្រយោគជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មទំហំ **១៩៥៨,៦៧ ហិកតា** ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និង ទំហំ **៨៣៧,៧៧ ហិកតា** រក្សាទុកជាដីសាធារណៈរបស់រដ្ឋ
- ផ្ទៃដីទំហំ **១៧១,៨១ ហិកតា** កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុនអ៊ីមឌីអេសនីហ័រណេ ដើម្បីធ្វើប្រទានកម្មទំហំ **១០៣,៩០ហិកតា** ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងដីទំហំ ៦៧,៩១ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (១) នៃអនុក្រឹត្យនេះ

p

១.២- ភូមិឈើទាលជ្រុំ ឃុំប្រម៉ោយ

- ផ្ទៃដីទំហំ ៥៩៨ ហិកតា កាត់ចេញពីដែនជម្រកសត្វព្រៃភ្នំសំកុស និងធ្វើអនុប្រយោគជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មទំហំ ៣៧៧ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និង ២២១ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ
- ផ្ទៃដីទំហំ ៦៦ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុនអ៊ឹមឌីអេសនីហ័រណ សម្រាប់ធ្វើប្រទានកម្មទំហំ ៥៧ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងដីទំហំ ៩ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកា ដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (២) នៃអនុក្រឹត្យនេះ

១.៣- ភូមិថ្មីកជ្រុំ ឃុំប្រម៉ោយ

- ផ្ទៃដីទំហំ ៧១៣,២៣ ហិកតា កាត់ចេញពីដែនជម្រកសត្វព្រៃភ្នំសំកុស និងធ្វើអនុប្រយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មទំហំ ៤១២,៩២ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និង ទំហំ ៣០០,៣១ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ
- ផ្ទៃដីទំហំ ៧២,៩៨ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុនអ៊ឹមឌីអេសនីហ័រណ សម្រាប់ធ្វើប្រទានកម្មទំហំ ៦៨ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៤,៩៨ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកា ដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (៣) នៃអនុក្រឹត្យនេះ។

មាត្រា ២.-

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តពោធិ៍សាត់ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ចំនួន ៨៣៥ គ្រួសារ នៅស្រុកវាលវែង ខេត្តពោធិ៍សាត់ ស្ថិតក្នុងភូមិ ឃុំ ដូចខាងក្រោម ៖

- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ **៤៧៧** គ្រួសារ នៅភូមិដីក្រហម ឃុំអន្លង់រាប
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១៩០ គ្រួសារ នៅភូមិឈើទាលជ្រុំ ឃុំប្រម៉ោយ
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១៦៨ គ្រួសារ នៅភូមិថ្មីកជ្រុំ ឃុំប្រម៉ោយ

មាត្រា ៣.-

ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិជាកម្មសិទ្ធិលើក្បាលដីសរុប ចំនួន ២.០២១ ក្បាលដី ក្នុងនោះ ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ៨៣៥ គ្រួសារ លើ ១.៩០៩ ក្បាលដី ដីវត្ត ០១ ក្បាលដី និងដីរដ្ឋ ១០៦ ក្បាលដី (ដីសាលារៀន ០៥ ក្បាលដី និងដីរក្សាបម្រុងទុករបស់រដ្ឋ ១០១ ក្បាលដី) ដែលនៅក្នុងភូមិ ឃុំ ស្រុក ដូចខាងក្រោម ៖

p

